អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

## ការបើកបញ្ជីមេធាវីរបស់អង្គភាពគាំពារការការពារក្តី

នៅថ្ងៃនេះអង្គភាពគាំពារការការពារក្តី (DSS) នៃអង្គជំនុំជម្រះវិសាមញ្ញចាប់ផ្តើមបើកបញ្ជីមេធាវីកម្ពុជា និង មេធាវីបរទេស ដែលអាចជ្រើសរើសដោយកូនក្តីដើម្បីការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។

ជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញ អាចការពារដោយសហមេធាវីកម្ពុជាមួយរូប និងសហមេធាវីបរទេសមួយរូប ។ ទាំងសហមេធាវីកម្ពុជា និង សហមេធាវីបរទេសមានសមត្ថភាពខាងផ្នែកនីតិវិធី និងច្បាប់ព្រហ្មទណ្ឌនៅកំរិតជាតិ និង អន្តរជាតិ ។ សហមេធាវីបរទេស មានបទពិសោធន៏ការងារយ៉ាងតិចដប់(១០)ឆ្នាំ ។ការបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី ត្រូវប្រតិបត្តិតាមនីតិវិធីដែលបញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុងអនុម័តដោយមន្ត្រីតុលាការនាថ្ងៃទី ១២ ខែ មិថុនា ២០០៧ និង បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តីអនុម័តនៅថ្ងៃទី ៩ ខែ កក្កដា ២០០៧ ។កាលពីដើមឆ្នាំនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រេចឲមេធាវីបរទេសបង់ថ្លៃចុះបញ្ជីចំនួន ៥០០ ដុល្លា ដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី ។

បេក្ខជន អាចដាក់ពាក្យសុំដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវីតាមរយៈគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញញ www.eccc.gov.kh ។

លោករ៉ូធីត ស្កីលបេក ប្រធានអង្គភាពគាំពារការការពារក្តីមានប្រសាសន៏ថា “យើងរំពឹងទុកថា នឹងមានមេធាវីនៅជុំវិញពិភពលោកដាក់ពាក្យសុំដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី។យើងបានទទួលដំណឹងស្តីពីការចាប់អារម្មណ៏របស់មេធាវីនៅអូស្ត្រាលី កាណាដា បារាំង ហុងកុង ជប៉ុន ម៉ាឡេស៊ី សាំងហ្គាពួ និងនៅចក្រភពអង់គ្លេស និង សហរដ្ឋអាមេរិក ។ ខ្ញុំជឿជាក់ថាយើងអាចបង្កើតក្រុមការពារដ៏ខ្លាំងមួយដើម្បីធានានូវការកាត់សេចក្តីដោយយុត្តិធម៏ដល់មនុស្សគ្រប់រូបនៅអង្គជំនុំជម្រះវិសាមញ្ញ” ។

សហមេធាវីទាំងពីរនឹងគាំទ្រដោយក្រុមការពារ ដែលមានសមាសភាពជាទីប្រឹក្សាពិគ្រោះយោបល់ផ្នែកច្បាប់ និង អ្នកគ្រប់គ្រងសំណុំរឿង ។ ស្របពេលជាមួយគ្នានេះអង្គភាពគាំពារការការពារក្តីសូមប្រកាសបើកនីតិវិធីជ្រើសរើសតំណែងទាំងនេះ ។

ថ្ងៃទី ៩ ខែ កក្កដា ២០០៧

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងលោក រាជ សម្បត្តិ មន្ត្រីព័ត៌មានផ្នែកទំនាក់ទំនងកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ១៥៦ ។